**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខ: ៣៩៥ សហវ.គ.អ

រាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០៨

# ប្រកាស

## ស្តីពី

## ការដឹកជញ្ជូន ការចែកចាយ និងការកាន់កាប់ទំនិញនៅក្នុងដែនគយ

## ទេសរដ្ឋមន្ត្រី

## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស / រកត / ០៧០៤ / ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែល ប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខនស / រកម / ០៧០៧ / ០១៧ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ២០០៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីគយ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- យោងតាមសំណូមពរការងារចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ ១.-**

ទំនិញនាំចូលទាំងអស់ជាកម្មវត្ថុនៃការត្រួតពិនិត្យរបស់រដ្ឋបាលគយ ។ ទំនិញទាំងនេះអាចត្រូវបានបញ្ចេញពីគយនៅមាត់ច្រកនាំចូល អាចដឹកជញ្ជូនទៅកាន់ការិយាល័យគយនានាក្រោមការឃ្លាំមើលរបស់គយដើម្បីបំពេញបែបបទបញ្ចេញទំនិញពីគយ ឬអាចដឹកជញ្ជូនទៅការិយាល័យគយដើម្បីនាំចេញក្រោមរបបឆ្លងកាត់ ។



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92, Sangkat Wat Phnom , Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

**ប្រការ ២.-**

នីតិវិធីគយលើការដឹកជញ្ជូន ការចែកចាយ និងការកាន់រក្សាទំនិញនាំចូល ត្រូវបានកំណត់ដូចខាងក្រោម ៖

ក. ក្នុងវង់អំណាចគយ ទំនិញនាំចូលទាំងអស់ ត្រូវអមភ្ជាប់ជាមួយនូវឯកសារនានាដែលបញ្ជាក់ថាទំនិញទាំងនេះត្រូវបាននាំចូលដោយស្របច្បាប់ដូចជាប្រតិវេទន៍គយច្បាប់ចម្លង បង្កាន់ដៃពន្ធច្បាប់ដើម ឬលិខិតអនុញ្ញាតដឹកជញ្ជូនច្បាប់ដើមភ្ជាប់ជាមួយបង្កាន់ដៃពន្ធច្បាប់ចម្លងដែលចេញដោយមន្ត្រីគយ និងរដ្ឋាករមានសមត្ថកិច្ច ។

ខ. ចំពោះទំនិញហាមឃាត់ និងទំនិញជាប់កម្រិតកំណត់ បន្ថែមលើការតម្រូវខាងលើ ត្រូវអមភ្ជាប់ផងដែរនូវលិខិតអនុញ្ញាតមានសុពលភាពដែលចេញដោយអាជ្ញាធរមានសមត្ថកិច្ច

គ. ចំពោះទំនិញដែលត្រូវបានកំណត់ចាត់ទុកជាទំនិញកំណត់ពិសេសក្រោមបញ្ញត្តិមាត្រា ៨ នៃច្បាប់ស្តីពីគយអាចជាកម្មវត្ថុនៃការតម្រូវបន្ថែមឱ្យបិតត្រាគយ និងការត្រួតពិនិត្យបន្ថែមតាមការកំណត់របស់នាយកទីចាត់ការគយនិងរដ្ឋាករ

ឃ. ចំពោះទំនិញដែលត្រូវបានលើកលែងពន្ធ ឬជាកម្មវត្ថុនៃរបបព្យួរពន្ធត្រូវអមភ្ជាប់ជាមួយនូវលិខិតអនុញ្ញាតមានសុពលភាពដែលចេញដោយរដ្ឋបាលគយ ។

**ប្រការ ៣.-**

លិខិតអនុញ្ញាតដឹកជញ្ជូន ដែលចេញដោយការិយាល័យគយនាមាត់ច្រកនាំចូលត្រូវបញ្ជាក់នូវអត្តសញ្ញាណច្បាស់លាស់នៃមធ្យោបាយដឹកជញ្ជូន គម្យដ្ឋានស្របច្បាប់នៃទំនិញ តម្រាយផ្លូវដឹកជញ្ជូន និងរយៈពេលនៃការដឹកជញ្ជូន ។ នាយកទីចាត់ការគយ និងរដ្ឋាករត្រូវចេញនូវសេចក្តីណែនាំពាក់ព័ន្ធនឹងតម្រូវការលិខិតអនុញ្ញាតដឹកជញ្ជូន លក្ខខណ្ឌនៃការចេញ និងការប្រើប្រាស់លិខិតអនុញ្ញាតនេះព្រមទាំងនីតិវិធីពាក់ព័ន្ធផ្សេងទៀត ។

បុគ្គលដែលកាន់រក្សានូវទំនិញ រួមទាំងអ្នកដឹកជញ្ជូន និងអ្នកចែកចាយត្រូវបង្ហាញទំនិញ និងលិខិតអនុញ្ញាតដឹកជញ្ជូន ឬឯកសារផ្សេងទៀតដូចរៀបរាប់ក្នុងប្រការ ២ ខាងលើដល់មន្ត្រីគយមានសមត្ថកិច្ចនៅពេលមានការតម្រូវ ។

**ប្រការ ៤.-**

បុគ្គលដែលកាន់រក្សាទំនិញហាមឃាត់ និងទំនិញជាប់កម្រិតកំណត់ ឬទំនិញកំណត់ពិសេស ត្រូវរក្សាទុកនូវឯកសារនានា ឬភស្តុតាងផ្សេងទៀតដែលបញ្ជាក់ថា ជាទំនិញផលិតក្នុងស្រុក ឬនាំចូលដោយស្របច្បាប់នៅក្នុងដែនគយ ។ ឯកសារទាំងនោះរួមមាន បង្កាន់ដៃពន្ធគយ វិក័យបត្រ កំណត់ត្រាផលិតកម្ម និងលិខិតអនុញ្ញាតអាជីវកម្ម។

**ប្រការ ៥.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៦.-**

ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជានាយកទីចាត់ការគយ និងរដ្ឋាករ អគ្គលេខាធិការ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋាន និងអង្គភាពនានាក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ព្រមទាំងបុគ្គល និងស្ថាប័នពាក់ព័ន្ធផ្សេងទៀត ត្រូវអនុវត្តតាមខ្លឹមសារប្រកាសនេះឲ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**គាត ឈន់**

**ចម្លងជូន ៖**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ទីស្តីការគណៈរដ្ឋមន្ត្រី "ដើម្បីជូនជ្រាប"
- ទីចាត់ការគយ និងរដ្ឋាករ
- ដូចប្រការ ៦
- សភាពាណិជ្ជកម្មកម្ពុជា "ដើម្បីសហការផ្សព្វផ្សាយ និងអនុវត្ត"
- រាជកិច្ច
- ឯកសារ- កាលប្បវត្តិ